# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២២៦ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងដឹកនាំការងាររៀបចំរបាយការណ៍ជាតិ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ជូនអង្គការសហប្រជាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំជាថ្មីនូវគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងកម្រិតនយោបាយដឹកនាំការងាររៀបចំរបាយការណ៍ជាតិ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ជូនអង្គការសហប្រជាជាតិ ដែលមានសមាសភាពដូចតទៅ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **កែវ រ៉េមី** | ទេសរដ្ឋមន្ត្រី និងជាប្រធាន គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ប្រធាន |
| ២. | ឯកឧត្តម **អ៊ិត រ៉ាឌី** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៣. | ឯកឧត្តម **ជេត ជាលី** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៤. | ឯកឧត្តម **កែវ សុទ្ធិ** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៥. | ឯកឧត្តម **ប៊ុន ហុន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៦. | ឯកឧត្តម **កាន់ ផារិទ្ធ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៧. | ឯកឧត្តម នាយឧត្តមសេនីយ៍ **យុនវុធ** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៨. | ឯកឧត្តម **ហៃល ចំរើន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៩. | ឯកឧត្តម **ថេង ច័ន្ទសង្វារ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១០. | ឯកឧត្តម **នាក់ សេរីគីរីន** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១១. | ឯកឧត្តម **ចាន់ សុវុឌ្ឍ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២. | ឯកឧត្តម **រដ្ឋ សារ៉ាវុធ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣. | ឯកឧត្តម **សួន សេរីរដ្ឋា** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៤. | ឯកឧត្តម **ដាវ អានសាន** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៥. | ឯកឧត្តម **សុខ ខាវ៉ាន់** | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៦. | ឯកឧត្តម **សុខ ប៊ុនថា** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៧. | លោកជំទាវ **ខៀវ បូរី** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកា |
| ១៨. | ឯកឧត្តម **ប៉ុច ប៊ុណ្ណាក់** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៩. | ឯកឧត្តម **ផៃ ប៊ុនឈឿន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ២០. | លោកជំទាវ **វង់ មយុរា** | រដ្ឋលេខាធិការក្រសួងអធិការកិច្ច | សមាជិកា |
| ២១. | លោកជំទាវ ឱសថការី **លី គឹមអេង** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិកា |
| ២២. | លោកជំទាវ **ប៉ែន មុនីមករា** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិកា |
| ២៣. | ឯកឧត្តម **ឱក តារាវិទ្ធិ** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៤. | ឯកឧត្តម **សោម ចំណាន** | រដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៥. | ឯកឧត្តម **ប៉ាល់ ចន្ទតារា** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៦. | ឯកឧត្តម **រោង ឈង** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ២៧. | ឯកឧត្តម **ប៉ែន វិបុល** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ២៨. | ឯកឧត្តម **ថោង សុជាតិ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាមន្ត្រីគ្រប់គ្រងជាន់ខ្ពស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | សមាជិក |
| ២៩. | លោកជំទាវ **អ៊ិច និពន្ធ** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិកា |
| ៣០. | លោកជំទាវ **ឆាំ ម៉ារី** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិកា |
| ៣១. | លោកជំទាវ **ឡុង សុនីតា** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិកា |
| ៣២. | ឯកឧត្តម **អ៊ីវ កាន** | ឧបការីអង្គភាពប្រឆាំងអំពើពុករលួយ | សមាជិក |

| | | | |
|---|---|---|---|
| ៣៣. | ឯកឧត្តម **វុន តូ** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៣៤. | លោកជំទាវ **ហ៊ាន ប៉ូលីណេ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិកា |
| ៣៥. | ឯកឧត្តម **ប្រាក់ ថាវអមិដា** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៣៦. | លោកជំទាវ **ញាណ សុចិត្រា** | អគ្គនាយក អភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិកា |
| ៣៧. | ឯកឧត្តម នាយឧត្តមសេនីយ៍ **មាស វិរិទ្ធ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ៣៨. | លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត **ប៉ុណ្ណ សំខាន់** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | សមាជិកា |
| ៣៩. | ឯកឧត្តម **សោម សូរីដា** | អគ្គលេខាធិការរង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | សមាជិក |
| ៤០. | ឯកឧត្តម **ប៉ា ប៉ុណ្ណារ៉ាដា** | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ៤១. | ឯកឧត្តមបណ្ឌិត **ឌី ខាំបូលី** | អគ្គលេខាធិការរង និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៤២. | ឯកឧត្តម **ស្រី ចាន់** | អគ្គលេខាធិការរងក្រុមប្រឹក្សាសកម្មភាពជនពិការ | សមាជិក។ |

**ប្រការ២ .-**

ក្រុមការងារអន្តរក្រសួងខាងលើនេះមានភារកិច្ចដូចតទៅ៖

- ដឹកនាំធ្វើសេចក្ដីព្រាងរបាយការណ៍ជាតិ ស្ដីពីការអនុវត្តសន្ធិសញ្ញាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅកម្ពុជា សម្រាប់ដាក់ជូនអង្គការសហប្រជាជាតិ មានជាអាទិ៍ របាយការណ៍ស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) របាយការណ៍ស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) របាយការណ៍ស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD) របាយការណ៍ស្ដីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ (CED) របាយការណ៍ស្ដីពីការពិនិត្យជាសកលតាមកាលកំណត់ (UPR) និងរបាយការណ៍ផ្សេងៗទៀត ដែលអង្គការសហប្រជាជាតិស្នើសុំ សម្រាប់ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចមុននឹងរៀបចំបញ្ជូនទៅអង្គការសហប្រជាជាតិ
- ពិនិត្យ និងលើកយោបល់ជូនរាជរដ្ឋាភិបាល លើសេចក្ដីព្រាងរបាយការណ៍នានា របស់អង្គការសហប្រជាជាតិ ដូចជារបាយការណ៍របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា របាយការណ៍របស់អ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ រួមទាំងរបាយការណ៍របស់អ្នកតំណាងផ្សេងៗទៀត នៃអង្គភាពសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិដែលបានដាក់ជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស តាមការប្រគល់ជូនពីប្រមុខរាជរដ្ឋាភិបាល។



ផ

**ប្រការ៣** .-

ក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។

ក្រុមការងារនេះ មានសិទ្ធិប្រើត្រារបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីសម្រួលការងារ និងមានទីស្នាក់ការនៅគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

**ប្រការ៤** .-

ក្រុមការងារអន្តរក្រសួងកម្រិតនយោបាយនេះ មានក្រុមការងារអន្តរក្រសួងកម្រិតបច្ចេកទេសជាជំនួយ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **អ៊ិត រ៉ាឌី** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ប្រធាន |
| ២. | ឯកឧត្តម **កែវ សុទ្ធិ** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៣. | លោកជំទាវ **អ៊ិច និពន្ធ** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៤. | លោកជំទាវ **ផាំ ម៉ារី** | អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | អនុប្រធាន |
| ៥. | ឯកឧត្តម **នូ ស្ថាបត្យា** | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ៦. | ឯកឧត្តម **ស៊ាង ផល្លា** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧. | ឯកឧត្តម **លឹម ស៊ុយហុង** | អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៨. | ឯកឧត្តម **ចាន់ វិចិត្រ** | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ៩. | ឯកឧត្តម **ស៊ិន ប៊ុនធឿន** | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១០. | ឯកឧត្តម **ញ៉ែម ប៊ុនធឿន** | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១១. | ឯកឧត្តម **វ៉ាន់ ច័ន្ទតារា** | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១២. | ឯកឧត្តម **ប៉ា ប៊ុណ្ណារ៉ាដា** | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ១៣. | ឯកឧត្តម **នូវ វឌ្ឍនៈ** | ទីប្រឹក្សាក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. | ឯកឧត្តម **សួរ ឌីម៉ា** | អនុប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ១៥. | ឯកឧត្តម **ចេង ម៉ានិត** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រត្តិបត្តិការអន្តរជាតិ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៦. | ឯកឧត្តម **ជ្រាយ ប៉ុម** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៧. | ឯកឧត្តម **ជា ចាន់ទុំ** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍ ក្រសួងផែនការ | សមាជិក |
| ១៨. | ឯកឧត្តម **សឿន ប៊ុនលី** | អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៩. | ឯកឧត្តម **ផុស សុវណ្ណ** | អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ក្រសួងព័ត៌មាន | សមាជិក |
| ២០. | ឯកឧត្តម **គឹម សុវណ្ណឌី** | អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិក |

| | | | |
|---|---|---|---|
| ២១. | ឯកឧត្តម **ស៊ុំ ធី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងជាអគ្គនាយកស្តីទីនៃអគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ ក្រសួងបរិស្ថាន | សមាជិក |
| ២២. | ឯកឧត្តម **ឡេង តុលា** | ជំនួយការ ឯកឧត្តមទេសរដ្ឋមន្ត្រី ឱម យ៉ិនទៀង | សមាជិក |
| ២៣. | ឧត្តមសេនីយ៍ឯក **សូ សំអន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ | សមាជិក |
| ២៤. | ឯកឧត្តម **ជួរ ជេតទីវន្ត** | ទីប្រឹក្សាក្រសួង និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ២៥. | លោក **ភាគ សុជា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៦. | លោក **បែន វិស្ណុ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ | សមាជិក |
| ២៧. | លោក **សរ ចិត្រា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៨. | លោក **សុខ ប៊ុនថន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២៩. | លោក **ថេង ធារិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៣០. | លោក **សុខ ចំណាន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៣១. | លោក **ចាន់ រស្មី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ ក្រសួងអធិការកិច្ច | សមាជិក |
| ៣២. | លោក **មាស កុសល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៣៣. | លោកវេជ្ជបណ្ឌិត **លន់ ច័ន្ទរស្មី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល | សមាជិក |
| ៣៤. | លោក **ចាន់ តូ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៣៥. | លោក **ភី សុគន្ធ** | អគ្គលេខាធិការរង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | សមាជិក |
| ៣៦. | លោក **ហែន សារិទ្ធ** | អគ្គាធិការរងក្រសួងមុខងារសាធារណៈ | សមាជិក |
| ៣៧. | លោក **សៅ សារ៉ន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការសាសនា ក្រសួងធម្មការ និងសាសនា | សមាជិក |

| | | | |
|---|---|---|---|
| ៣៨. | ឧត្តមសេនីយ៍ឯក **ថោង សុគន្ធា** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ៣៩. | ឧត្តមសេនីយ៍ត្រី **តែ សុថារេត** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | សមាជិក |
| ៤០. | ឯកឧត្តមបណ្ឌិត **ស៊ិន សេងហុក** | អគ្គលេខាធិការរង និងជាប្រធាននាយដ្ឋាននីតិកម្ម ក្រសួងអប់រំ យុវជននិងកីឡា | សមាជិក |
| ៤១. | លោក **ផៃ ច័ន្ទត្រាសិទ្ធ** | ប្រធាននាយកដ្ឋាននីតិកម្ម ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៤២. | លោក **ស៊ូ គឹមព្រឹទ្ធា** | ប្រធាននាយដ្ឋាននីតិកម្ម ក្រសួងទេសចរណ៍ | សមាជិក |
| ៤៣. | លោក **ស៊ឹម សិរី** | ជំនួយការ និងជាអនុប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | សមាជិក |
| ៤៤. | ឯកឧត្តម **ហង្ស វណ្ណៈ** | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងជាប្រធានផ្នែកគាំពារជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា | សមាជិក |
| ៤៥. | លោក **ហុក លី** | ប្រធានផ្នែកសិទ្ធិជនពិការ ក្រុមប្រឹក្សាសកម្មភាពជនពិការ | សមាជិក។ |

**ប្រការ៥ .-**

ក្រុមការងារអន្តរក្រសួងកម្រិតបច្ចេកទេសខាងលើនេះ មានភារកិច្ចដូចតទៅ៖

- ពិនិត្យ សិក្សា និងរៀបចំតាក់តែងសេចក្តីព្រាងរបាយការណ៍ជាតិ ស្តីពីការអនុវត្តសន្ធិសញ្ញាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅកម្ពុជា សម្រាប់ដាក់ជូនអង្គការសហប្រជាជាតិ មានជាអាទិ៍ របាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) របាយការណ៍ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR) របាយការណ៍ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (CERD) របាយការណ៍ស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ (CED) របាយការណ៍ស្តីពីការពិនិត្យជាសកលតាមកាលកំណត់ (UPR) និងរបាយការណ៍ផ្សេងៗទៀត ដែលអង្គការសហប្រជាជាតិស្នើសុំ ដើម្បីដាក់ជូនក្រុមការងារអន្តរក្រសួងកម្រិតនយោបាយដឹកនាំការងាររៀបចំរបាយការណ៍ជាតិ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជាជូនអង្គការសហប្រជាជាតិ ពិនិត្យ និងសម្រេច
- ពិនិត្យ សិក្សា និងលើកអនុសាសន៍ ជូនក្រុមការងារអន្តរក្រសួងកម្រិតនយោបាយដឹកនាំការងាររៀបចំរបាយការណ៍ជាតិ ស្តីពីសិទ្ធិមនុស្សនៅកម្ពុជាជូនអង្គការសហប្រជាជាតិ ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីព្រាងរបាយការណ៍នានារបស់អង្គការសហប្រជាជាតិ ដូចជារបាយការណ៍អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា របាយការណ៍របស់អ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ រួមទាំងរបាយការណ៍របស់អ្នកតំណាងផ្សេងៗទៀត នៃអង្គភាពសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ដែលបានដាក់ជូនរាជរដ្ឋាភិបាល
- ផ្តល់ព័ត៌មាន ស្ថិតិ ទិន្នន័យរបស់ក្រសួង អង្គភាពសាមី ដល់ក្រុមការងាររៀបចំរបាយការណ៍សិទ្ធិមនុស្សរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា តាមការស្នើសុំ
- បំពេញភារកិច្ចផ្សេងៗទៀតពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស តាមការប្រគល់ឱ្យពីប្រធានក្រុមការងារអន្តរក្រសួង។



ឞ

**ប្រការ៦ .-**

គ្រប់របាយការណ៍ជាតិស្ដីពីសិទ្ធិមនុស្សនៅកម្ពុជាដូចមានរៀបរាប់ក្នុងប្រការ២ និងប្រការ៥ នៃសេចក្ដីសម្រេចនេះ នឹងត្រូវបញ្ជូនដោយផ្ទាល់ទៅប្រមុខរាជរដ្ឋាភិបាល ដើម្បីស្នើសុំការពិនិត្យ និងសម្រេចក្នុងការដាក់ជូនអង្គការសហប្រជាជាតិ បន្ទាប់ពីឆ្លងកាត់ការប្រជុំពិនិត្យដោយក្រុមការងារអន្តរក្រសួងកម្រិតបច្ចេកទេស និងក្រុមការងារអន្តរក្រសួងកម្រិតនយោបាយ។

**ប្រការ៧ .-**

ក្រុមការងារអន្តរក្រសួងកម្រិតនយោបាយ និងក្រុមការងារអន្តរក្រសួងកម្រិតបច្ចេកទេស មានសិទ្ធិអញ្ជើញមន្ត្រីជំនាញជាតិ និងអន្តរជាតិ មកចូលរួមផ្ដល់យោបល់បន្ថែមលើការងារនេះ។

សមាជិកក្រុមការងារអន្តរក្រសួងកម្រិតនយោបាយ និងសមាជិកក្រុមការងារអន្តរក្រសួងកម្រិតបច្ចេកទេស មានសិទ្ធិរៀបចំក្រុមការងារ និងប្រើប្រាស់មន្ត្រីក្រោមឱវាទក្នុងស្ថាប័នសាមី ដើម្បីចូលរួមអនុវត្តភារកិច្ច ដូចមានចែងក្នុងប្រការ២ និងប្រការ៥ នៃ សេចក្ដីសម្រេចនេះ។

សមាជិក នៃក្រុមការងាអន្តរក្រសួងកម្រិតនយោបាយ និងក្រុមការងារអន្តរក្រសួងកម្រិតបច្ចេកទេស អាចប្រើប្រាស់ថវិការបស់ស្ថាប័នសាមី ដើម្បីបំពេញបេសកកម្ម។

**ប្រការ៨ .-**

ការប្រព្រឹត្តទៅនៃក្រុមការងារអន្តរក្រសួងទាំងពីរខាងលើនេះ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិការបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ និងប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងាររបស់ក្រុមការងារទាំងពីរឱ្យមានប្រសិទ្ធភាព។

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៩ រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ